**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ១១៤៦/១៩ ក.អ.ជ

ថ្ងៃចន្ទ ៦ រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៩

# របាយការណ៍

# វឌ្ឍនភាពការងារប្រចាំខែមិថុនា ឆ្នាំ ២០១៩ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## I. សេចក្តីផ្តើម

ក្នុងខែមិថុនា ឆ្នាំ២០១៩ សមិទ្ធផលនៃការអនុវត្តផែនការសកម្មភាពកាន់តែលេចធ្លោឡើងបង្ហាញយ៉ាងច្បាស់ពីការផ្សារភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត សេវាសាធារណៈ ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនជនបទ ។ សកម្មភាពរស់រវើកប្រចាំថ្ងៃរបស់ប្រជាជននៅជនបទ បានបញ្ជាក់ពីការប្រែផ្លាស់ស្ថានភាពរស់នៅឲ្យកាន់តែស៊ីវិល័យជាងមុន តាមរយៈការប្រើប្រាស់សម្ភារៈប្រចាំថ្ងៃក្នុងលំហានតាមគ្រួសារមួយភាគធំដូចជា ទូរទស្សន៍ ម៉ូតូ ទូរស័ព្ទដៃ អគ្គិសនី បង្គន់អនាម័យ អណ្តូងទឹកស្អាត ឬបណ្តាញទឹកតាមប្រព័ន្ធទឹកស្អាត ( PVC Pice) ។ល។ សុខភាពផ្លូវកាយ និងផ្លូវចិត្តកាន់តែរឹងមាំជាងមុន ព្រោះប្រជាជនពុំមានអារម្មណ៍ភ័យខ្លាចសង្គ្រាម ឬចលាចលក្នុងស្រុកនោះទេ ហេតុនេះប្រជាជនមានពេលវេលាគ្រប់គ្រាន់ប្រកបរបរកសិកម្ម ធ្វើជំនួញចិញ្ចឹមជីវិតដោយទឹកចិត្តរីករាយបំផុត ។ ក្នុងគោលដៅបង្កើនប្រាក់ចំណូលតាមគ្រួសារនីមួយៗនៅជនបទ ក្រសួងអភិវឌ្ឍន៍ជនបទបានដាក់ចេញនូវគោលនយោបាយមួយសមស្របនឹងនិន្នាការរីកចំរើននាពេលបច្ចុប្បន្ន និងទិសដៅទៅអនាគតតាមរយៈកម្មវិធីចំនួន ០៤ ដែលនឹងត្រូវអនុវត្តនៅឆ្នាំ២០២០ ខាងមុខនេះ ដើម្បីជានាលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរបស់ប្រជាជន នៅជនបទឲ្យ កាន់តែល្អប្រសើរឡើងថែមទៀតទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌នៅជនបទ ។ ក្នុងខែមិថុនា ឆ្នាំ២០១៩ នេះក្រសួងសម្រេចបានដូចខាងក្រោម៖

## II. អំពីការងារគ្រប់គ្រងរបស់ក្រសួង

### ១. ការងាររដ្ឋបាល និងបុគ្គលិក

ដោយគិតត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០១៩ មន្ត្រីរាជការក្របខណ្ឌសរុបមានចំនួន ១ ៨០៤នាក់ ប្រៀបធៀបនឹងចំនួនមន្ត្រីរាជការកាលពីដំណាច់ខែឧសភា ឆ្នាំ២០១៩ មានការថយចុះចំនួន ០៥នាក់ ដោយការផ្ទេរក្របខណ្ឌចេញ និងលុបឈ្មោះចេញពីក្របខណ្ឌ ។ ក្រសួងបានទទួលលិខិតចូលចំនួន ១៨៩ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន ១៨៣ច្បាប់ ចុះលេខប្រកាស និងសេចក្តីសម្រេចនានាចំនួន ០១៥ច្បាប់ និងចុះលេខលិខិតបេសកកម្មចំនួន ២៦១ច្បាប់ ។


អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល dap.mrd@gmail.com

២. ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤

ក្នុងខែមិថុនា ឆ្នាំ ២០១៩ លេខាធិការដ្ឋានទទួលបានសំណើ សំណូមពររបស់ប្រជាពលរដ្ឋ នៅមូលដ្ឋានតាមរយៈវេទិកាសាធារណៈថ្នាក់ជាតិ សរុបចំនួន ០២ ករណី។ ចំពោះសំណើចំនួន ០១ ករណី នៅខេត្តស្ទឹងត្រែង ត្រូវបានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បញ្ចូលក្នុងផែនការសកម្មភាពរបស់មន្ទីរក្នុងឆ្នាំ២០២០រួចហើយ ។

៣. ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

ក្នុងខែមិថុនា នេះ ក្រសួងបានអនុវត្តចំណាយធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១៩ សម្រេចបាន ៖

- ចំណាយចរន្តអនុវត្តបានចំនួន ៣ ២២៨ ២៧៨ ៦៣០ រៀល ស្មើនឹង ២,៤៦% នៃច្បាប់ថវិកា
- ចំណាយមូលធនអនុវត្តបានចំនួន ៦ ៧៣១ ២៣៨ ០០០ រៀល ស្មើនឹង ៣,៥៤% នៃច្បាប់ថវិកា ។

៤. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ

- រៀបចំសិក្ខាសាលាស្តីពី "ការផ្លាស់ប្តូរបទពិសោធន៍លើការងារ រៀបចំផែនការបន្សាំការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យអភិវឌ្ឍន៍ជនបទ ឆ្នាំ២០១៩" នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត សៅ ជីវ័ន្ត** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ
- រៀបចំសិក្ខាសាលាស្តីពី "ការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ និងព័ត៌មានរបស់ក្រសួងអភិវឌ្ឍន៍ជនបទ" នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត សៅ ជីវ័ន្ត** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ
- ចុះត្រួតពិនិត្យការធ្វើអង្កេតទិន្នន័យអភិវឌ្ឍន៍ជនបទ និងពង្រឹងស្ថិតិ នៅខេត្តក្រចេះ និងស្ទឹងត្រែង
- ចុះពិនិត្យការអនុវត្តផែនការឆ្នាំ ២០១៩ និងណែនាំការរៀបចំផែនការកម្មវិធីឆ្នាំ ២០២០ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ និងកំពង់ធំ
- ចូលរួមជាគ្រូបង្គោល និងជាអ្នកសម្របសម្រួលសិក្ខាសាលារៀនសូត្រ និងពិគ្រោះយោបល់ស្តីពីការគ្រប់គ្រងប្រព័ន្ធទិន្នន័យ វិស័យផ្គត់ផ្គង់ទឹកស្អាត សុខភាព និងអនាម័យជនបទ ជំហាន២ នៅខេត្តកំពត កំពង់ឆ្នាំង និងកំពង់ធំ
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់អន្តរក្រសួងស្តីពីពិធីសារចែករំលែកទិន្នន័យ និងកម្មវិធីជាតិសម្រាប់រាយការណ៍ទិន្នន័យសូចនាករអភិវឌ្ឍន៍ (CAMSTAT) នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ
- បានផ្តល់សំណើសុំហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការ រវាងក្រសួងការបរទេស និងសហប្រតិបត្តិអន្តរជាតិ ជូនអង្គការ ចំនួន ០២ គឺ អង្គការស៊ី ប៊ី អិន កម្ពុជា (CBN) និងអង្គការ Mennonite Central Committee (MCC)

- បានផ្តល់សំណើសុំអន្តរាគមន៍ ដើម្បីចុះបញ្ជីសុំស្លាកលេខ ONG សម្រាប់រថយន្តចំនួន ០២ គ្រឿង របស់អង្គការសហគ្រាសអភិវឌ្ឍន៍អន្តរជាតិកម្ពុជា ( iDE )
- ចូលរួមធ្វើបទបង្ហាញស្តីពី វឌ្ឍនភាព និងការអនុវត្តគម្រោង មេគង្គ ឡានឆាង នៅក្នុងប្រទេសកម្ពុជា ជាមួយភាគីចិន នៅទីស្តីការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានចុះពិនិត្យការងាររបស់អង្គការក្រៅរដ្ឋាភិបាលនៅក្នុងខេត្តក្រចេះ និងត្បូងឃ្មុំ ។

**៥. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- រៀបចំតាមដាន និងត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពដំណាក់កាលទី៣ ឆ្នាំ២០១៩ និងត្រៀមរៀបចំផែនការសកម្មភាពដំណាក់កាលទី៣ ឆ្នាំ២០២០ ( KPIs-2020 )
- រៀបចំសិក្ខាសាលាបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកផែនការ និងហិរញ្ញវត្ថុ នៅខេត្តកែប ក្រោមអធិបតីភាព **ឯកឧត្តម សួស គង់** រដ្ឋលេខាធិការប្រចាំការ និងជាប្រធានក្រុមការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រសួងអភិវឌ្ឍន៍ជនបទ
- ត្រៀមរៀបចំវគ្គបណ្តុះបណ្តាល FMIS នៅខេត្តបាត់ដំបង ។

**៦. ការងារអធិការកិច្ច និងសវនកម្ម**

- ចុះធ្វើសវនកម្មលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ថវិកាតាមកម្មវិធី ឆ្នាំ ២០១៨ - ២០១៩ និងចុះពិនិត្យជាក់ស្តែងការងារសាងសង់ ជួសជុលអណ្តូងទឹក និងសាងសង់បង្គន់អនាម័យដោយប្រើប្រាស់ថវិការដ្ឋនៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ០២ រួមមាន ខេត្តកំពង់ចាម និងត្បូងឃ្មុំ ។

## III. សកម្មភាពការងារជំនាញ

**១. ការងារអភិវឌ្ឍន៍ផ្លូវជនបទ**

- គម្រោងស្ថាបនា កែលម្អផ្លូវ និងសំណង់សិល្បការ្យ ឆ្នាំ២០១៩ មាន ៨២ គម្រោងកំពុងដំណើរការការដ្ឋានបានចំនួន ៦៩គម្រោង លទ្ធផលគិតជាមធ្យម ៤៣.៧២ %
- ការងារថែទាំផ្លូវលក្ខណៈខួប ឆ្នាំ២០១៩ មាន ចំនួន ២៨ គម្រោង ស្មើនឹង ៦៣ ខ្សែ ដំណើរការការដ្ឋានលទ្ធផលគិតជាមធ្យម ៥៥.១១ %
- ការងារថែទាំផ្លូវលក្ខណៈប្រចាំ ឆ្នាំ២០១៩ មានចំនួន ៤០ គម្រោង ស្មើនឹង ៣៦៩ ខ្សែ ដំណើរការការដ្ឋានលទ្ធផលគិតជាមធ្យម ១៧.៤៨ %
- ចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចុះត្រួតពិនិត្យ និងវាយតម្លៃបញ្ចប់សុពលភាពបានចំនួន ០៤ គម្រោង អនុវត្តដោយនាយកដ្ឋានស្ថាបនា និងវិស្វកម្ម ក្រសួងមហាផ្ទៃ នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ និងនាយកដ្ឋានផ្លូវលំជនបទ លើការងារស្ថាបនា និងជួសជុល
- ចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចរចាថ្លៃបានចំនួន ១៤គម្រោង អនុវត្តដោយនាយកដ្ឋានបញ្ជាការដ្ឋានវិស្វកម្មកងទ័ពជើងគោក នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ និងនាយកដ្ឋានផ្លូវលំជនបទ លើការងារស្ថាបនា
- ចូលរួមកិច្ចប្រជុំ Kick off Meeting និង Wrap-up Meeting ជាមួយក្រុមបេសកកម្មធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីការពិនិត្យ និងតាមដានវឌ្ឍនភាពនៃការអនុវត្តគម្រោង

កែលម្អផ្លូវជនបទដំហានទី២ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព **ឯកឧត្តម សួស គង់** រដ្ឋលេខាធិការប្រចាំការក្រសួងអភិវឌ្ឍន៍ជនបទ

- ចូលរួមកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងសម្របសម្រួលគម្រោង សាងសង់ ស្តារ ជួសជុល និងកម្មវិធីថែទាំផ្លូវថ្នល់ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ២. ការងារផ្គត់ផ្គង់ទឹកជនបទ

- ខួងអណ្តូង បានចំនួន ០៥ អណ្តូង និងកំពុងបន្តខួងអណ្តូងបន្តទៀត នៅខេត្តកណ្តាល
- ចុះត្រួតពិនិត្យ និងវាយតម្លៃសំណង់អណ្តូង ស្រះ អាងត្រង់ទឹកភ្លៀង បានចំនួន ១៦ អណ្តូង នៅខេត្តកំពង់ចាម និងកណ្តាល
- ចូលរួមកិច្ចប្រជុំចរចារថ្លៃលើគម្រោងការងារសាងសង់អណ្តូង អាងត្រង់ទឹកភ្លៀង ប្រព័ន្ធចែកចាយទឹកខ្នាតតូច និងស្តារស្រះសហគមន៍ចំនួន ១៨ គម្រោង
- ចុះត្រួតពិនិត្យ វាយតម្លៃសំណង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ (អណ្តូងទឹក) និងចុះសិក្សាទីតាំងសាងសង់អណ្តូងស្នប់ នៅខេត្តកំពង់ធំ សៀមរាប និងបន្ទាយមានជ័យ
- ចូលរួមកិច្ចប្រជុំ ស្តីពីការរៀបចំសេចក្តីព្រាងកម្មវិធី/គម្រោងអភិវឌ្ឍន៍ និងជំនួយបច្ចេកទេសឆ្នាំ ២០២០-២០២២ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមសម្របសម្រួលកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់ក្រុមបេសកកម្មធនាគារអភិវឌ្ឍន៍អាស៊ី ក្រោមអធិបតីភាព **ឯកឧត្តម ទ្រី មេង** រដ្ឋលេខាធិការ នៅនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ
- ចូលរួមសិក្ខាសាលាស្តីពីការប្រមូលទឹកភ្លៀងជាដំណោះស្រាយសម្រាប់ការផ្គត់ផ្គង់ទឹកនៅតំបន់ជនបទ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងករណីសិក្សា នៅរាជបណ្ឌិត្យសភាកម្ពុជា ។

## ៣. ការងារថែទាំសុខភាព និងអនាម័យជនបទ

- ផ្តល់ចានបង្គន់តាមផ្ទះឯកជន បានចំនួន ២៩៥ ខ្នងផ្ទះ នៅខេត្តព្រះសីហនុ
- រៀបចំសិក្ខាសាលា "រៀនសូត្រ និងពិគ្រោះយោបល់ ស្តីពីការគ្រប់គ្រងប្រព័ន្ធទិន្នន័យវិស័យទឹកស្អាត សុខភាព និងអនាម័យជនបទ" ក្រោមអធិបតីភាព **ឯកឧត្តម ទ្រី មេង** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទ ទាំង២៥ រាជធានី-ខេត្ត
- រៀបចំពិធីប្រកាស ជាឃុំសម្រេចបានការបញ្ឈប់បន្ទោរបង់ពាសវាលពាសកាល (ODF) របស់ឃុំព្រៃឈរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង និងឃុំក្រាំងស្បូវ ស្រុកឈូក ខេត្តកំពត
- ចូលរួមប្រជុំថ្នាក់តំបន់ស្តីពី " ASWA DFID Leaning Exchange and Annual Review Meeting " នៅទីក្រុងបាងកក ប្រទេសថៃ
- ចុះធ្វើការវាយតម្លៃ និងផ្សព្វផ្សាយគោលការណ៍ណែនាំកម្មវិធីទឹកស្អាត និងអនាម័យ តាមសាលារៀន និងសហគមន៍នៅខេត្តក្រចេះ កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ចាម ត្បូងឃ្មុំ និងសៀមរាប ដែលមានអ្នកចូលរួមសរុបចំនួន ៣១៦នាក់ ស្រី ១៣១នាក់
- បានចុះអប់រំអនាម័យនៅសហគមន៍តាមភូមិគោលដៅនៅខេត្តក្រចេះ កំពង់ឆ្នាំង កំពង់ស្ពឺ ស្វាយរៀង កោះកុង ព្រះសីហនុ ប៉ៃលិន កំពង់ចាម ឧត្តរមានជ័យ សៀមរាប កែប និងត្បូងឃ្មុំ ដែលមានអ្នកចូលរួមសរុប ចំនួន ៣ ៣០៥នាក់ ស្រី ១ ៨៣៦នាក់

- បានចុះត្រួតពិនិត្យតាមដាន និងបំផុសការលើកកម្ពស់អនាម័យនៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដែលមានប្រជាជនចូលរួមចំនួន ១៣៣នាក់ និងស្រី ៦៧នាក់
- បានពិនិត្យតាមដានការអនុវត្តកម្មវិធី CLTS និង SC WASH នៅខេត្តក្រចេះ ។

**៤. ការងារអភិវឌ្ឍន៍សហគមន៍**

- ចុះតាមដានការធ្វើបច្ចុប្បន្នភាព និងពិភាក្សាការងារពង្រឹងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅខេត្តស្វាយរៀង និងព្រៃវែង
- ចុះពិនិត្យ និងតាមដានការអនុវត្តគម្រោងលើកកំពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ នៅខេត្តកែប
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានបន្តវគ្គបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ ចំនួន ០៤ មុខជំនាញ ដែលមានសិក្ខាកាមសរុបចំនួន ១២១ នាក់ ស្រី ៥៥ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានធ្វើការផ្សព្វផ្សាយជ្រើសរើសសិស្សឲ្យចូលរៀនវគ្គបណ្ដុះបណ្ដាល នៅឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស ។

**៥. ការងារបណ្ដុះបណ្ដាល**

- មន្ត្រីចូលរួមសិក្ខាសាលាក្នុងប្រទេស ចំនួន ៦៤៧នាក់ ក្នុងនោះស្រីចំនួន ១៤២នាក់
- មន្ត្រីចូលរួមវគ្គបណ្ដុះបណ្ដាលក្នុងប្រទេស ចំនួន ៧៧នាក់ ក្នុងនោះស្រីចំនួន ០៩នាក់
- មន្ត្រីចូលរួមទស្សនកិច្ចសិក្សាក្នុងប្រទេស ចំនួន ០១នាក់ ក្នុងនោះស្រីចំនួន ០១នាក់
- បានរៀបចំឯកសារចាត់បញ្ជូនមន្ត្រី ដើម្បីទៅចូលរួមវគ្គបណ្ដុះបណ្ដាល ក្នុងប្រទេស និងក្រៅប្រទេស ចំនួន ០៣លើក
- ផ្សព្វផ្សាយសេចក្ដីជូនដំណឹងអាហារូបករណ៍ ការជ្រើសរើសបុគ្គលិក និងរៀបចំឯកសារសំណើបញ្ជូនមន្ត្រី ចូលរួមវគ្គបណ្ដុះបណ្ដាលក្រៅប្រទេស ចំនួន ០៤លើក
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង បានបន្តដំណើរការបណ្ដុះបណ្ដាលសម្រាប់ឆមាសទី១ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៩៦នាក់ ស្រី ៧២នាក់ លើ ០៤មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង បានបន្តដំណើរការបណ្ដុះបណ្ដាលសម្រាប់ឆមាសទី១ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ១៥០នាក់ ស្រី ៦៥នាក់ លើ ០៧ មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានបន្តដំណើរការបណ្ដុះបណ្ដាលរយៈពេលវែង ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៧៦នាក់ ស្រី ៦៩នាក់ លើ ០២មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង បានបញ្ចប់វគ្គបណ្ដុះបណ្ដាលរយៈពេលវែង និងបានបើកវគ្គរយៈពេលខ្លី ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៨០ នាក់ ស្រី ៣២ នាក់ លើ ០៣ មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តពោធិ៍សាត់ បានបន្តដំណើរការបណ្ដុះបណ្ដាលសម្រាប់ឆមាសទី១ ដែលមានសិក្ខាកាមចូលរៀនបន្ថែម សរុបចំនួន ១២០នាក់ ស្រី ៩៥នាក់ លើ ០៤ មុខជំនាញ (បន្ថែមវគ្គបណ្ដុះបណ្ដាលដំណាំស្រូវ)

- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពត បានបន្តដំណើរការបណ្តុះបណ្តាលសម្រាប់ឆមាសទី១ ដែលមានសិក្ខាកាមចូលរៀនបន្ថែម សរុបចំនួន ៧៧នាក់ ស្រី ៤០នាក់ លើ ០៣ មុខជំនាញ (បន្ថែមវគ្គបច្ចេកទេសជួសជុល និងថែទាំអណ្តូងស្នប់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ បានកំពង់បន្តចុះផ្សព្វផ្សាយ ជ្រើសរើសទីតាំង និងបម្រុងឯកសារមេរៀនបន្ថែម លើ០២មុខជំនាញ សម្រាប់គម្រោងបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនាពេលខាងមុខ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបន្ទាយមានជ័យ បានបន្តផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមចូលរៀនតាមវគ្គនីមួយៗ និងបន្តដំណើរការបណ្តុះបណ្តាលសម្រាប់ឆមាសទី១ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៤៥នាក់ ស្រី ២៦នាក់ (កើនឡើងចំនួន ០២ នាក់) លើមុខវិជ្ជាភាសាអង់គ្លេស
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តសៀមរាប បន្តរៀបចំផែនការ និងស្រង់ទិន្នន័យអ្នកមានបំណងចូលរៀន ព្រមទាំងបន្តការផ្សព្វផ្សាយពីគម្រោងវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនាពេលខាងមុខ ។

៦. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

- គិតត្រឹមថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៩ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់ បានផ្តល់ឥណទានសរុបចំនួន ៤ ១៦២ ៧៥៧ ៨៣៥ រៀល (បួនពាន់មួយរយហុកសិបពីរលានប្រាំពីររយហាសិបប្រាំពីរពាន់ប្រាំបីរយសាមសិបប្រាំរៀល) ស្មើនឹង ១ ០៥៩ ៩១៥,៤២ ដុល្លារអាមេរិក (មួយលានហាសិបប្រាំបួនពាន់ប្រាំបួនរយដប់ប្រាំដុល្លារនិងសែសិបពីរសេន) (១USD=៤០០០រៀល) មានអ្នកខ្ចីសរុបចំនួន ៤ ៣៥៤ នាក់នៅភូមិគោលដៅចំនួន ១៩៥ ភូមិ ៧១ឃុំ ៣២ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥
- ធ្វើការបូកសរុប និងសម្របសម្រួលគាំទ្រផ្នែកបច្ចេកទេសគ្រប់គ្រងធនាគារស្រូវដល់សហគមន៍ដែលមានស្រូវសរុបចំនួន ១០ ០០០ គ.ក ស្ថិតនៅដៃសមាជិកកំពុងប្រើប្រាស់សរុបចំនួន ៨៦នាក់ ស្រី ៦៤នាក់ នៅខេត្តស្វាយរៀង
- ចុះបណ្តុះបណ្តាលចំនួន ០២វគ្គ ដែលសហការជាមួយអង្គការភ្លែនអន្តរជាតិកម្ពុជា ស្តីពីគំនិតផ្តួចផ្តើមបង្កើតអាជីវកម្មខ្នាតតូច និងបច្ចេកទេសផលិតសាប៊ូលាងចាន បានចំនួន ០២វគ្គ ដែលមានសិក្ខាកាមចូលរួមចំនួន ៣០នាក់ ស្ត្រី ០៩នាក់ ។

៧. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច

- ចូលរួមពិធីផ្សព្វផ្សាយ អំពីគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងដំណើរការស្វ័យអត្តសញ្ញាណជនជាតិដើមភាគតិចព័រ នៅខេត្តពោធិ៍សាត់
- ចូលរួមពិធីប្រគល់លិខិតទទួលស្គាល់អត្តសញ្ញាណជនជាតិដើមភាគតិចកួយ នៅខេត្តកំពង់ធំ
- ចូលរួមកិច្ចប្រជុំពេញអង្គ របស់សហគមន៍ដើម្បីពិនិត្យ និងអនុម័តលើខ្លឹមសារព្រាងបទបញ្ជាផ្ទៃក្នុង ស្តីពី ការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ សហគមន៍ជនជាតិដើមភាគតិចព្រៅ និងលុន នៅខេត្តរតនគិរី

- ចូលរួមកិច្ចប្រជុំពេញអង្គ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈ និងគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិច ចំនួន ០២សហគមន៍ នៅខេត្តរតនគិរី ។

៨. ការងារយេនឌ័រ

- ចូលក្រាបថ្វាយបង្គំគាល់ **សម្តេចព្រះមហាក្សត្រីព្រះវររាជមាតាជាតិខ្មែរ** ក្នុងឱកាសចម្រើនព្រះជន្មព្រះវររាជមាតាជាតិខ្មែរ ព្រះប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នៅព្រះបរមរាជវាំង
- ចូលរួមសិក្ខាសាលាអន្តរវិស័យថ្នាក់ជាតិ ស្តីពីការលើកកម្ពស់សុវត្ថិភាពស្ត្រី និងការបញ្ជ្រាបយេនឌ័រ ទៅនឹងការប្រែប្រួលអាកាសធាតុ នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ
- ចូលរួមកិច្ចប្រជុំប្រចាំត្រីមាស របស់គណៈកម្មាធិការដឹកនាំ និងសម្របសម្រួលការងារយេនឌ័រ និងការប្រែប្រួលអាកាសធាតុ នៅក្រសួងកិច្ចការនារី ។

៩. ការងារប្រយុទ្ធនឹងជំងឺអេដស៍

- រៀបចំប្រជុំក្រុមការងារដើម្បីរៀបចំផែនការសម្រាប់អនុវត្តការងារ ឆ្នាំ២០១៩ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

១០. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ

- រៀបចំតារាងផែនការថវិកា ឆ្នាំ២០១៩ សម្រាប់ការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់មុខងារនីមួយៗ
- បន្តរៀបចំមុខងារទាំ ០៣ ដែលត្រូវផ្ទេរដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

## IV. **ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការផ្សេងៗ**

១. គម្រោងកែលម្អផ្លូវជនបទ ជំហាន ២

អនុវត្តក្នុងខេត្តគោលដៅចំនួន១០ គឺ ខេត្តត្បូងឃ្មុំ កំពង់ចាម តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ គិតត្រឹមដំណាច់ ខែមិថុនានេះ គម្រោងសម្រេចបាន ៖

- ខេត្តត្បូងឃ្មុំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១៩៣,៩ គ.ម សម្រេចបាន ១០០%
- ខេត្តតាកែវ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១០៤,០៨គ.ម សម្រេចបាន ៤៤,៤៤%
- ខេត្តកំពង់ស្ពឺ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ខ្សែ មានប្រវែងសរុប ១៦១,៦០គ.ម សម្រេចបាន ៥៨,៥៦%
- ខេត្តកំពង់ឆ្នាំង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១២៦,៣០គ.ម សម្រេចបាន ៤៦,៣៨%
- ខេត្តកំពង់ធំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៤ខ្សែប្រវែង ១១៣,៤០គ.ម សម្រេចបាន ៤៨,៩៤%
- ខេត្តសៀមរាប : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៦ខ្សែ មានប្រវែងសរុប ១២៦,២០ គ.ម សម្រេចបាន ៣១,៤៥%

- ខេត្តពោធិ៍សាត់ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ខ្សែ មានប្រវែងសរុប ១២៥,៥០គ.ម សម្រេចបាន ៩៦,៩៣%
- ខេត្តបាត់ដំបង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៨ខ្សែ មានប្រវែងសរុប ១០១,២០គ.ម សម្រេចបាន ៩៦,៨៨%
- ខេត្តបន្ទាយមានជ័យ :បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៥ខ្សែ មានប្រវែងសរុប ៩០,៧០ គ.ម សម្រេចបាន ៩២,៨១%
- ខេត្តកំពង់ចាម : បាន និងកំពុងដំណើរការសាងសង់ផ្លូវក្រាលបេតុងចំនួន ០៦ខ្សែ មានប្រវែងសរុប ៥០គ.ម សម្រេចបាន ១០០% ។

**២. គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទដំហានទី ៦**

គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទជំហានទី ៦ ជាគម្រោងសហហិរញ្ញប្បទានឥតសំណងរវាងរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តាមរយៈធនាគារ KfW និងរាជរដ្ឋាភិបាលកម្ពុជា អនុវត្តនៅខេត្តបន្ទាយមានជ័យ។ គិតត្រឹមដំណាច់ ខែឧសភានេះ គម្រោងសម្រេចបាន ៖

- ស្រុកមង្គលបុរី : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៣ខ្សែ មានប្រវែងសរុប ២៧,២០ គ.ម សម្រេចបាន ១៨,៩០%
- ស្រុកអូរជ្រៅ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០១ខ្សែ មានប្រវែងសរុប ២០ គ.ម សម្រេចបាន ២៣% ។

**៣. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ**

គម្រោងសាច់ប្រាក់ពលកម្ម សម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ មានរយៈពេល ០៣ឆ្នាំ គិតចាប់ពី ឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩ និងផ្តោតលើការស្តារ និងកែលំអផ្លូវជនបទ ដោយត្រូវអនុវត្តជា ២ជំហាន ដែលអនុវត្តក្នុងខេត្តគោលដៅចំនួន ១២ គឺ ខេត្តកណ្តាល តាកែវ ស្វាយរៀង កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ស្ពឺ ព្រៃវែង និងខេត្តឧត្តរមានជ័យ ។ គិតត្រឹមខែមិថុនានេះ គម្រោងដែលបានស្នើសុំក្រាលគ្រួសក្រហមចំនួន ១៤១គម្រោង បាននិងកំពុងអនុវត្តការងារ បានចំនួន ១២៨គម្រោង ប្រវែងសរុប ៥៤៥ ១៧៧ម៉ែត្រ ដោយឡែកសម្រាប់ជំហាន ២ គម្រោង បាននិងកំពុងអនុវត្តចំនួន ១៦០គម្រោង ប្រវែង ១៦១ ៤០៦ម៉ែត្រ ។

**៤. គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទី ២**

- សាងសង់ថ្នាលហាលលាមកមានដំបូលថ្លាពេញ (Model3) និងថ្នាលហាលលាមកមានភ្ជាប់ឡជីវឧស្ម័ន (Model1) នៅខេត្តបាត់ដំបង សម្រេចបាន ១០០%
- ជួសជុលស្រះសហគមន៍បានចំនួន ០១ស្រះ សម្រេចបាន ១០០% នៅស្រុកបាកាន ខេត្តពោធិ៍សាត់
- ខួងអណ្តូងបានចំនួន ០៥ អណ្តូង និងចាក់បេតុងអាមេលើខឿនអណ្តូងសម្រេចបាន ១២២ អណ្តូង ស្រុកកណ្តៀង នៅខេត្តពោធិ៍សាត់ ។

## V. សេចក្តីសន្និដ្ឋាន

ស្ថានភាពជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងប្រទេស ពិសេសប្រជាជនដែលកំពុងរស់នៅតាមជនបទត្រូវបានរាជរដ្ឋាភិបាលកម្ពុជាគិតគូរយកចិត្តទុកដាក់យ៉ាងខ្លាំងតាមរយៈការផ្តល់ជូនសេវាសាធារណៈទៅជិតលំនៅឋានរបស់ប្រជាពលរដ្ឋដូចជា សាលារៀន មណ្ឌលសុខភាព អណ្តូងទឹក ស្រះទឹក បណ្តាញទឹកស្អាត បង្គន់អនាម័យ អគ្គិសនី ពិសេសផ្លូវថ្នល់បានចូលទៅដល់ក្នុងភូមិ ឃុំ ស្រុករបស់ប្រជាពលរដ្ឋ ។ ចំណែកសកម្មភាពសេដ្ឋកិច្ច រដ្ឋបានសាងសង់ផ្សារទាំងនៅទីក្រុង និងជនបទ ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការប្រកបជំនួញបង្កើនសកម្មភាពសេដ្ឋកិច្ចធ្វើឲ្យប្រទេសជាតិមានការរីកចម្រើនលើគ្រប់វិស័យ ដែលកំពុងជំរុញឲ្យមានការផ្លាស់ប្តូរលក្ខខណ្ឌរស់នៅរបស់ប្រជាជនបានល្អប្រសើរ ធានាបាននូវគុណភាព និងគុណតម្លៃនៃជីវិតរបស់ប្រជាពលរដ្ឋកម្ពុជា ៕

**រដ្ឋមន្ត្រី**

**បណ្ឌិត អ៊ឹក រ៉ាប៊ុន**